**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធនធានទឹក និងឧតុនិយម**

លេខ ៣១០សជណ ធទឧ

# សេចក្តីជូនដំណឹង

## ស្តីពី ស្ថានភាពអាកាសធាតុនៅព្រះរាជាណាចក្រកម្ពុជា

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការតាមដានលើស្ថានភាពអាកាសធាតុរួចមក ឃើញថា : បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងទទួលរងឥទ្ធិពលពីខ្យល់មូសុងឦសាន និងជ្រលងសម្ពាធខ្ពស់ស៊ីបេរី ។ យោងតាមការព្យាករណ៍ ចាប់ពីថ្ងៃទី 17 ខែធ្នូ ឆ្នាំ 2014 តទៅ ខ្យល់មូសុងឦសាន និងជ្រលងសម្ពាធខ្ពស់ស៊ីបេរី នឹងបង្កើនឥទ្ធិពលកាន់តែខ្លាំង មកលើតំបន់ភាគខាងជើងនៃព្រះរាជាណាចក្រកម្ពុជា ។ លក្ខណៈបែបនេះ នឹងធ្វើឱ្យស្ថានភាពធាតុអាកាសនៅព្រះរាជាណាចក្រកម្ពុជា **ចុះត្រជាក់ ចាប់ពីថ្ងៃទី 17 ខែធ្នូ ឆ្នាំ 2014** ( ក្នុងរយៈពេលប្រមាណ ០១ សប្តាហ៍ ) ដោយក្នុងនោះមាន :

- **តំបន់ភ្នំ និងតំបន់ខ្ពង់រាប** : រួមមាន តំបន់ជួរខ្នងភ្នំដងរែក ខេត្តឧត្តរមានជ័យ ព្រះវិហារ មណ្ឌលគិរី និងខេត្តរតនគិរី សីតុណ្ហភាពអប្បបរមា មានពី 15-17 °C, សីតុណ្ហភាពអតិបរមា មានពី 25-27 °C ។
- ខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន សៀមរាប កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ ក្រចេះ និងខេត្តស្ទឹងត្រែង សីតុណ្ហភាពអប្បបរមា មានពី 17-19 °C, សីតុណ្ហភាពអតិបរមា មានពី 26-29 °C ។
- រាជធានីភ្នំពេញ ខេត្តពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល ព្រៃវែង ស្វាយរៀង និងខេត្តតាកែវ សីតុណ្ហភាពអប្បបរមា មានពី 18-20 °C, សីតុណ្ហភាពអតិបរមា មានពី 28-31 °C ។
- ខេត្តកោះកុង ព្រះសីហនុ កំពត និងខេត្តកែប សីតុណ្ហភាពអប្បបរមា មានពី 22-24 °C, សីតុណ្ហភាពអតិបរមា មានពី 31-33 °C ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន **ជាពិសេសចំពោះវីរៈកងទ័ពដែលកំពុងឈរជើងតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ** ជ្រាបជាព័ត៌មាន និងសូមបង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ ចំពោះស្ថានភាពអាកាសធាតុ ដែលចុះត្រជាក់នេះ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

**លឹម គានហោ**

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh